របាយការណ៍វិភាគបណ្ដាញសង្គម

# ការវិភាគមតិយោបល់របស់ទំព័រហ្វេសប៊ុកសារព័ត៌មាន AFP

## បទសម្ភាស លោក ហ៊ុន ម៉ាណែត ស្ដីពីមជ្ឈមណ្ឌលឆបោក

*ទំនោរចិត្ត / ទម្រង់នៃការបន្ទំដែលមានការរៀបចំ / ការប្រើប្រាស់ bot / និន្នាការមតិយោបល់*

| | |
|---|---|
| **ប្រធានបទ** | ផុសរបស់ AFP: "Scam centres 'destroying' Cambodia's economy, PM tells AFP" |
| **Post ID** | 1343523617820612 |
| **ថេរវេលានៃការបញ្ចេញមតិយោបល់** | ២៦-២៧ កុម្ភៈ ឆ្នាំ២០២៦ |
| **ការបរិច្ឆេទនៃរបាយការន៍** | ២ មីនា ឆ្នាំ២០២៦ |
| **ចំនួនមតិយោបល់សរុប** | ១៤៨៩ មតិយោបល់ មកពី ១៤៥៣ គណនី |
| **កំណត់សម្គាល់អ្នកវិភាគ** | របាយការណ៍នេះពិនិត្យមើលតែមតិយោបល់ជាភាសាអង់គ្លេស និងខ្មែរប៉ុណ្ណោះ។ មតិយោបល់ជាភាសាផ្សេងទៀត (ថៃ អារ៉ាប់) ត្រូវបានចាត់ចូលក្នុងប្រភេទនៃមតិយោបល់ “មិនអាចចាត់ថ្នាក់បាន” និងមិនត្រូវបានយកមកវិភាគទេ។ |

# គោលបំណងនៃរបាយការណ៍

ការសិក្សានេះធ្វើឡើងដើម្បីឆ្លើយសំណួរសំខាន់ៗចំនួនប្រាំអំពីមតិយោបល់ជាសាធារណៈនៅលើទំព័រហ្វេសប៊ុករបស់ AFP អំពីកិច្ចសម្ភាសន៍របស់ នាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ស្តីពីមជ្ឈមណ្ឌលបោកប្រាស់៖

| # | សំណួរសម្រាប់ការស្រាវជ្រាវ |
|---|---|
| ១ | តើមតិយោបល់ទាំងនោះពិតជាត្រឹមត្រូវមែនទេ? តើមតិយោបល់ទាំងនោះឆ្លុះបញ្ចាំងពីមតិពិតប្រាកដ ឬមតិទាំងនោះត្រូវបានបង្ហោះជាផ្នែកមួយនៃយុទ្ធនាការដែលមានការរៀបចំទុក? |
| ២ | តើប្រធានបទត្រូវបានផ្លាស់ប្តូរទេ? តើអ្នកបញ្ចេញមតិយោបាល់បានសរសេរពីប្រធានបទនៃមជ្ឈមណ្ឌលបោកប្រាស់ ឬក៏មានក្រុមណាមួយបានប្រើការបញ្ចេញមតិយោបល់របស់ពួកដើម្បីផ្សព្វផ្សាយរឿង ឬប្រធានបទផ្សេង? |
| ៣ | តើមានមតិយោបល់ដូចៗគ្នាត្រូវបានចម្លង និងចែករំលែកដែរឬទេ? តើមានមតិយោបល់ប៉ុន្មានដែលចម្លងជាទៅវិញទៅមក ហើយតើទម្រង់គំរូ (របស់មតិយោបល់) ផ្សេងៗគ្នាប៉ុន្មានត្រូវបានប្រើប្រាស់? |
| ៤ | តើមានការប្រើប្រាស់កម្មវិធីស្វ័យប្រវត្តិ (bot) ដែរឬទេ? តើមានគណនីដែលបានសរសេរបង្ហោះមតិលឿនពេកដែលទំនងមិនមានជាមនុស្សដែរឬទេ? ឬដែលបង្ហាញថាជាកម្មវិធីកុំព្យូទ័រ ដែលត្រូវបានប្រើជំនួសឲ្យមនុស្សពិត? |
| ៥ | តើគណនីទាំងនោះកំពុងកំណត់គោលដៅអ្នកអានជាក់លាក់ណាមួយ តាមរយៈជម្រើសភាសាដែរឬទេ? ហើយមានគណនីណាមួយកំពុងលាក់បាំងអត្តសញ្ញាណរបស់ពួកគេដែរឬទេ? តើភាសាដែលប្រើនៅក្នុងមតិយោបល់ឆ្លុះបញ្ចាំងពីអត្តសញ្ញាណពិតរបស់អ្នកសរសេរ ឬឆ្លុះបញ្ចាំងពីអ្នកដែលពួកគេចង់ឱ្យបានឃើញសារនោះ? តើមានសញ្ញាណាមួយដែលបង្ហាញថា ម្ចាស់គណនីអាចនឹងកំពុងសរសេរជាភាសាដែលមិនមែនជាភាសាកំណើតរបស់ខ្លួន ដើម្បីនិយាយដោយផ្ទាល់ទៅកាន់ជាតិសាសន៍ ឬក្រុមជាក់លាក់ណាមួយដែរឬទេ? |

# សេចក្តីសង្ខេបរបាយការណ៍

របាយការណ៍នេះពិនិត្យមើលមតិយោបល់ចំនួន ១,៤៨៩ លើការបង្ហោះនៅលើហ្វេសប៊ុករបស់ AFP។ ការបង្ហោះនោះគឺនិយាយអំពីនាយករដ្ឋមន្ត្រីកម្ពុជា លោក ហ៊ុន ម៉ាណែត ដែលបានធ្វើការសម្ភាសអំពីមជ្ឈមណ្ឌលឆបោកបោក នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងបទសម្ភាសន៍របស់គាត់ គាត់បានបដិសេធការអះអាងថារដ្ឋាភិបាលបានជួយប្រតិបត្តិករឆបោក។

ការវិភាគនេះ ពិនិត្យពីមតិយោបល់ដែលបានផ្សាយរយៈពេលពីរថ្ងៃ៖ ថ្ងៃទី ២៦-២៧ ខែកុម្ភៈ ឆ្នាំ ២០២៦។ របាយការណ៍នេះ សិក្សាពីអ្វីដែលមនុស្សម្នាបាននិយាយថា តើមតិយោបល់ទាំងនោះជាការពិត ឬត្រូវបានចម្លង និងថាតើគណនីណាមួយទំនងជាអាចត្រូវបានប្រើប្រាស់ដោយប្រព័ន្ធស្វ័យប្រវត្តិ (bot) ដែរឬទេ។

### ការរកឃើញទី១ — មតិយោបល់ភាគច្រើនត្រូវបានចម្លងគ្នា (ដូចៗគ្នា)

មតិយោបល់ស្ទើរតែ ៨ ក្នុងចំណោម ១០ ដែលស្មើនឹង ៧៩.៨% គឺជាការចម្លងដូចៗគ្នា។ មតិយោបល់ដូចៗគ្នាទាំងនេះត្រូវបានបង្ហោះដោយគណនីផ្សេងៗគ្នា រហូតដល់ ១៩ ដង។ នេះគឺជាសញ្ញានៃយុទ្ធនាការដែលបានរៀបចំទុក មិនមែនជាការពិភាក្សាជាសាធារណៈតាមធម្មតានោះទេ។

### ការរកឃើញទី២ — ប្រធានត្រូវបានផ្លាស់ប្តូរ

មតិយោបល់ច្រើនជាងគេ (៩៧៣ ក្នុងចំណោម ១៤៨៩) មិនបាននិយាយអំពីមជ្ឈមណ្ឌលឆបោកនោះទេ។ ផ្ទុយទៅវិញ មតិយោបល់ទាំងនេះបានបង្វែសារទៅជាការមិនចុះសម្រុងគ្នារវាងព្រំដែនកម្ពុជា-ថៃទៅវិញ។ នេះគឺជាបន្លំទូទៅមួយដើម្បីផ្លាស់ប្តូរប្រធានបទ និងលាក់បាំងបញ្ហាដើម។

### ការរកឃើញទី៣ — ភស្តុតាងនៃការប្រើប្រព័ន្ធស្វ័យប្រវត្តិដើម្បីផ្ទុសមតិយោបល់ (bot)

គណនីពីរបានបង្ហោះសារវែងៗក្នុងរយៈពេលត្រឹម ៣ ទៅ ១៣ វិនាទីនៃការបង្ហោះមតិយោបល់របស់ពួកគេពីមួយទៅមួយ។ មនុស្សមិនអាចវាយអក្សរលឿនបែបនេះបានទេ។ នេះបង្ហាញយ៉ាងច្បាស់ថា កម្មវិធីកុំព្យូទ័រ មិនមែនមនុស្សទេ ដែលត្រូវបានប្រើដើម្បីបង្ហោះមតិយោបល់ទាំងនេះ។

### ការរកឃើញទី៤ — មតិយោបល់ដែលបានផ្ទុសឡើងក្នុងរយៈពេលខ្លី

មតិយោបល់ដែលបានចម្លងស្ទើរតែដូចៗគញនាទាំងអស់បានលេចឡើងក្នុងរយៈពេលត្រឹមតែពីរម៉ោងប៉ុណ្ណោះ (ម៉ោង 21:00–22:00 UTC ថ្ងៃទី ២៦ ខែកុម្ភៈ)។ ការផ្ទុះភ្លាមៗ បន្ទាប់មកឈប់ភ្លាមៗនេះ មិនមែនជាឥរិយាបថរបស់អ្នកអានធម្មតាទេ។ វាបង្ហាញថាក្រុមគណនីជាច្រើន ត្រូវបានបើក និងបិទតំណាលៗគ្នា។

## ១.ទិដ្ឋភាពទូទៅ

តារាងខាងក្រោមបង្ហាញពីតួលេខសំខាន់ៗនៅក្នុងការសិក្សានេះ៖

| | | | |
|---|---|---|---|
| **១៤៨៩** | **១៤៥៣** | **៧៩.៨%** | **១៦០** |
| **មតិយោបល់សរុប**<br>២៦-២៧ កុម្ភៈ ឆ្នាំ២០២៦ | **គណនីជាក់លាក់**<br>គណនីដែលបានផ្ទូសច្រើន | **មតិយោបល់ចម្លង**<br>១១៨៨ នៃ ១៤៨៩ | **មតិយោបល់ដែលជាទម្រង់**<br>ត្រូវបានគណនីផ្សេងៗយកទៅប្រើប្រាស់ |

ដំបូង តួលេខមើលទៅធម្មតា។ គណនីភាគច្រើនត្រូវបានបង្ហោះតែម្តងៗប៉ុណ្ណោះ។ ប៉ុន្តែខ្លឹមសារដែលពួកគេបានបង្ហោះស្ទើរតែទាំងអស់ត្រូវបានចម្លងពីអត្ថបទដែលត្រៀមរួចជាស្រេច។ មតិយោបល់ប្រហែលបួនក្នុងចំណោមប្រាំមិនមែនជារបស់ដើមទេ។ នេះគឺជារឿងមិនធម្មតាទេ ហើយបង្ហាញថាការផ្ទូសមតិយោបល់ត្រូវគេបានរៀបចំ។

## ២.និន្នាការមតិយោបល់តាមម៉ោង

តារាងខាងក្រោមបង្ហាញពីចំនួនមតិយោបល់ដែលត្រូវបានបង្ហោះក្នុងរយៈពេលមួយម៉ោង។ ពេលវេលារបស់មតិយោបល់ទាំងអស់ដែលបានបង្ហាញ គិតតាមម៉ោងសកល (UTC)។




*Figure 1: Number of comments per hour. Data source: FB Post ID 1343523617820612*

### ការសង្កេតឃើញសំខាន់ៗ

សកម្មភាពការប្រើប្រាស់ការបញ្ចេញមតិយោបល់បង្ហាញពីលំនាំយ៉ាងច្បាស់លាស់មួយ។ មានមតិយោបល់តិចតួចណាស់នៅពេលព្រឹក និងពេលរសៀល។ បន្ទាប់មកមានការកើនឡើងបន្តិចបន្តួចនៅម៉ោង 16:00 UTC (មតិ 107)។ បន្ទាប់ពីនោះ ចំនួនបានកើនឡើងយ៉ាងខ្លាំង៖

- 21:00 UTC — មតិយោបល់ចំនួន ៣៤៥ បានផុសក្នុងរយៈពេល ១ម៉ោង
- 22:00 UTC — មតិយោបល់ចំនួន ៨១៤ បានផុសក្នុងរយៈពេល ១ម៉ោង (ខ្ពស់ជាងម៉ោងផ្សេងៗ)
- 23:00 UTC — មានតែ ១៧មតិយោបល់ទេ ដែលបង្ហាញពីការឈប់ផុសភ្លាមៗ

លំនាំនៃការកើនឡើង និងធ្លាក់ចុះនេះក្នុងរយៈពេលត្រឹមតែពីរម៉ោងប៉ុណ្ណោះគឺមិនធម្មតាទេ។ ជាធម្មតា ការបញ្ចេញមតិអាចចំណាយពេលអស់រយៈពេលជាច្រើនម៉ោង។ ចំណុចខ្ពស់ខ្លាំង គឺនៅម៉ោង 22:00 UTC បន្ទាប់មកដោយការឈប់ភ្លាមៗបង្ហាញថាក្រុមគណនីមួយចំនួនធំត្រូវបានធ្វើឱ្យសកម្មក្នុងពេលតែមួយ បានបង្ហោះសាររបស់ពួកគេ ហើយបន្ទាប់មកបានឈប់។

> **កំណត់ចំណាំសំខាន់អំពីការកើនឡើង**
> មតិយោបល់ចំនួន ៨១៤ ដែលបានបង្ហោះនៅម៉ោង 22:00 UTC គឺប្រហែល ៥៥% នៃមតិយោបល់សរុបចំនួន ១៤៨៩ គឺបង្ហោះក្នុងរយៈពេលតែមួយម៉ោង។ មតិយោបល់ទាំងនេះស្ទើរតែទាំងអស់នេះគឺជាអត្ថបទដែលបានចម្លង។ លំនាំពេលវេលានេះ រួមផ្សំជាមួយនឹងអត្រាចម្លងខ្ពស់ខ្លាំង គឺជាសូចនាករដ៏រឹងមាំមួយនៃប្រតិបត្តិការដែលមានការរៀបចំ។

## ៣. អ្វីដែលសាធារណៈជនបាននិយាយ៖ ការវិភាគទំនោរចិត្ត

មតិយោបល់នីមួយៗត្រូវបានដាក់ចូលទៅក្នុងប្រភេទមតិយោបល់តាមក្រុមមួយនិមួយៗដោយផ្អែកលើអត្ថន័យរបស់មតិយោបល់ទាំងនោះ។ តារាងខាងក្រោមនេះ បង្ហាញពីលទ្ធផល៖

| ក្រុម | មតិយោបល់ | ចែកចាយ | ន័យរបស់សារ |
|---|---|---|---|
| **ទំនោរកម្ពុជា — ការការពារព្រំដែន** | ៩៧៣ | ៦៥.៣% | កម្ពុជាធ្វើតាមច្បាប់អន្តរជាតិ ប្រទេសថៃឈ្លានពាន |
| **ទំនោរកម្ពុជា — គាំទ្រការកំចាត់ការឆបោក** | ២៥ | ១.៧% | រដ្ឋាភិបាលធ្វើកិច្ចការល្អក្នុងការប្រឆាំងនឹងមជ្ឈមណ្ឌលឆបោក |
| **រិះគន់ លោក ហ៊ុន ម៉ាណែត** | ៧១ | ៤.៨% | ចម្ងល់ចំពោះការលើឡើងរបស់ លោក នាយករដ្ឋមន្ត្រី ឬសកម្មភាពរបស់រដ្ឋាភិបាល |
| **ទំនោរថៃ** | ១ | ០.០៧% | គាំទ្រជំហប្រទេសថៃ |

| ក្រុម | មតិយោបល់ | ចែកចាយ | ន័យរបស់សារ |
|---|---|---|---|
| **ធម្មតា / ផ្តោតលើដំណោះស្រាយ** | ៨ | ០.៥៤% | ផ្តល់ការយល់ឃើញមានតុល្យភាព ឬផ្តល់ជាដំណោះស្រាយ |
| **មិនអាចចាត់ថ្នាក់បាន** | ៤១១ | ២៧.៦% | មតិយោបល់ជា រូប Emoji អត្ថន័យមិនច្បាស់ ឬសារមិនមែនភាសាខ្មែរ/អង់គ្លេស |
| **សរុប** | **១៤៨៩** | **១០០%** | |

### ៣.១ ទំនោកម្ពុជា — ការការពារព្រំដែន (មតិយោបល់ ចំនួន៩៧៣ ស្មើនឹង ៦៥.៣%)

នេះគឺជាក្រុមធំបំផុតដែលមាន ៦៥.៣% នៃមតិយោបល់ទាំងអស់។ ប៉ុន្តែ មតិយោបល់ទាំងនេះមិននិយាយអំពីមជ្ឈមណ្ឌលឆបោកនោះទេ។ ពួកគេនិយាយអំពីជម្លោះព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃទៅវិញ។ នេះមានន័យថា ជិតពីរភាគបីនៃមតិយោបល់ទាំងអស់មិនអើពើនឹងប្រធានបទនៃអត្ថបទផ្សាយរបស់ AFP ទាំងស្រុងនោះទេ។

មតិយោបល់ទាំងនេះ មានដូចជា៖

- "Cambodia obeys law. Thailand breaks rules." — បានបង្ហោះដោយគណនីចំនួន ១៤ ផ្សេងៗគ្នាដែលមានពាក្យដូចគ្នាបេះបិទ
- "Cambodia respects borders. Thailand crosses them." — បង្ហោះដោយគណនីចំនួន ១៤ ផ្សេងៗគ្នា
- "Thailand attacks it." — បង្ហោះដោយគណនីចំនួន ១៥ ផ្សេងៗគ្នា
- "Thailand rejects peaceful solutions." — បង្ហោះដោយគណនីចំនួន ១៣ ផ្សេងៗគ្នា
- "កម្ពុជាគាំទ្រសន្តិភាព និងជ្រើសរើសច្បាប់អន្តរជាតិ ខណៈដែលថៃគិតតែអំណាច និងសង្គ្រាមបដិសេធច្បាប់អន្តរជាតិ។" — បានបង្ហោះដោយគណនីចំនួន ១៩ ដែលមានអត្ថបទដូចគ្នា

ការផ្លាស់ប្តូរប្រធានបទក្នុងផ្នែកមតិយោបល់ទៅជាប្រធានបទផ្សេង គឺជាវិធីសាស្ត្រដែលគេស្គាល់ថាប្រើក្នុងប្រតិបត្តិការនៃការជះឥទ្ធិពលនៅលើប្រព័ន្ធអ៊ីនធឺណិត។ វិធីនេះត្រូវបានធ្វើឡើងដើម្បីរុញច្រានការជជែកវែកញែកពីប្រធានបទពិតប្រាកដចេញ។

### ៣.២ ការរិះគន់លោក ហ៊ុន ម៉ាណែត (មតិយោបល់ចំនួន ៧១ ស្មើនឹង ៤.៨%)

មានមតិយោបល់មួយចំនួនតូចបានសួរអំពីការថ្លែង របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ឬបានសម្តែងការសង្ស័យអំពីតួនាទីរបស់រដ្ឋាភិបាលនៅក្នុងឧស្សាហកម្មឆបោក។ មតិយោបល់ទាំងនេះហាក់ដូចជាត្រូវបានសរសេរដោយអ្នកប្រើប្រាស់ពិតប្រាកដ។ ពួកគេប្រើពាក្យផ្សេងៗគ្នា ហើយត្រូវបានបង្ហោះនៅពេលវេលាផ្សេងៗគ្នា។ មតិយោបល់ដែលមានការចូលចិត្តច្រើនជាងគេនៅក្នុងសំណុំទិន្នន័យទាំងមូល គឺ "He's a PM. or an actor?"។

### ៣.៣ ទំនោរប្រទេសថៃ (មតិយោបល់ចំនួន ១ ស្មើនឹង ០.១%)

មានតែមតិយោបល់មួយប៉ុណ្ណោះដែលត្រូវបានរកឃើញថាគាំទ្រជំហររបស់ប្រទេសថៃ។ នេះជារឿងគួរឱ្យចាប់អារម្មណ៍ ពីព្រោះសារនៅក្នុងផ្នែកមតិយោបល់យ៉ាងច្រើន គឺប្រឆាំងនឹងប្រទេសថៃ។ អវត្តមានស្ទើរតែទាំងស្រុងនៃទំនោរគាំទ្រប្រទេសថៃ ទោះបីជាមានយុទ្ធនាការប្រឆាំងនឹងប្រទេសថៃក៏ដោយ។

***កំណត់សំគាល់៖*** *អ្នកសរសេរ និងវិភាគរបាយការណ៍នេះអាចអាន និងយល់បានតែភាសាខ្មែរ និងភាសាអង់គ្លេសប៉ុណ្ណោះ។ មតិយោបល់ដែលសរសេរជាភាសាផ្សេងទៀត - ដូចជាភាសាថៃ ភាសាអារ៉ាប់ ឬអក្សរផ្សេងទៀត - ត្រូវបានដាក់ក្នុងប្រភេទ"មិនអាចចាត់ថ្នាក់បាន" ហើយមិនត្រូវបានរាប់បញ្ចូលក្នុងការវិភាគនេះទេ។ វាអាចទៅរួចដែលថាមតិយោបល់មួយចំនួនទាំងនេះបង្ហាញពីការគាំទ្រចំពោះប្រទេសថៃ ឬជំហរផ្សេងទៀតដែលមិនត្រូវបានបង្ហាញក្នុងផ្នែក ៣.៣នេះ។*

### ៣.៤ មតិយោបល់មិនអាចចាត់ថ្នាក់បាន (មតិយោបល់ចំនួន ៤១១ ស្មើនឹង ២៧.៦%)

មតិយោបល់ជាងមួយភាគបួន (២៧.៦%) មិនអាចដាក់ចូលទៅក្នុងប្រភេទនៃមតិយោបល់ ច្បាស់លាស់បានទេ។ ទាំងនេះរួមមានមតិយោបល់ដែលមានតែរូបសញ្ញាអារម្មណ៍(emoji) មតិយោបល់ខ្លីៗដែលគ្មានអត្ថន័យច្បាស់លាស់ និងសំខាន់គឺ មតិយោបល់ជាភាសាផ្សេងក្រៅពីភាសាខ្មែរ និងភាសាអង់គ្លេស (សូមមើលកំណត់សំគាល់ ផ្នែក៣.៣ ខាងលើ)។ មតិយោបល់ទាំងនេះមិនត្រូវបានវិភាគលើទំនោរនោះទេ។

### ៣.៥ មតិយោបល់ធម្មតា (មិនមានទំនោ) ដែលផ្តោតលើដំណោះស្រាយ

មតិយោបល់មួយចំនួនតូចប៉ុណ្ណោះ ដែលមានចំនួនប្រាំបី បានផ្តល់នូវទស្សនៈដែលមានមិនមានទំនោ និងផ្តោតលើដំណោះស្រាយពិតប្រាកដដែលបានស្នើឡើងចំពោះបញ្ហាមជ្ឈមណ្ឌលឆបោក។ ទោះបីជាមានចំនួនតិចតួចក៏ដោយ ក៏វាមានតម្លៃសំអានការអានដែរ។ មតិយោបល់ទាំងនេះ គឺផ្តោតលើការផ្តល់យោបល់ទៅលើគោលនយោបាយពិតប្រាកដក្នុងចំណោមមតិយោបល់ទាំងអស់។

#### ដំណោះស្រាយដែលបានស្នើឡើងដោយអ្នកបញ្ចេញមតិមិនមានទំនោ

មតិយោបល់ដែលមិនមានទំនោទាំងប្រាំបីនេះបានលើកឡើងនូវគំនិតសំខាន់ៗចំនួនបួន៖

- យុទ្ធសាស្ត្រនៃការអនុវត្តច្បាប់ឲ្យបានពេញលេញ៖ មតិយោបល់នេះដែលទទួលបានការចូលចិត្តច្រើនបំផុត (ពីគណនី Roth BKK, គឺចំនួន 1) ដែលបាននិយាយឱ្យមានវិធីសាស្ត្រពេញលេញដែលលើសពីការវាយឆ្មក់របស់ប៉ូលីសរយៈពេលខ្លី។ មតិយោបល់បានរាយចំណុចជាក់លាក់ដូចជា ការបង្ការ ការស៊ើបអង្កេត ការអប់រំសាធារណៈ ការកែលម្អបទប្បញ្ញត្តិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ការផ្តល់យោបល់បែបនេះ គឺឃើញមានសឹងតែដូចគ្នា ពីការសរសេររបស់គណនីដែលមានឈ្មោះថា Chou។
- កំណែទម្រង់សេដ្ឋកិច្ច៖ គណនីឈ្មោះ Ly Sok បានសរសេរយ៉ាងសាមញ្ញថា "We need honest economy not scam economy." សំណេរដើម - “យើងត្រូវការសេដ្ឋកិច្ចស្មោះត្រង់ មិនមែនសេដ្ឋកិច្ចបោកប្រាស់ទេ” សំណេរបកប្រែជាភាសាខ្មែរ។ មតិយោបល់នេះបង្ហាញពីក្តីបារម្ភកាន់តែធំ ថាសេដ្ឋកិច្ចកម្ពុជាបានពឹងផ្អែកខ្លាំងពេកលើប្រាក់ចំណូលពីបទល្មើសព្រហ្មទណ្ឌ ហើយត្រូវការកំណែទម្រង់រចនាសម្ព័ន្ធ។
- ការទទួលខុសត្រូវកម្រិតខ្ពស់៖ អ្នកបញ្ចេញមតិយោបល់ពីរនាក់បានចង្អុលបង្ហាញដោយផ្ទាល់ទៅលើមន្ត្រីមានអំណាច។ គណនី សាន វីរៈ បានសរសេរថា "We need to clean from top echelon I think." សំណេរដើម - “ខ្ញុំគិតថាយើងត្រូវសម្អាតពីថ្នាក់លើ” សំណេរបកប្រែជាភាសាខ្មែរ។ ចំណែកឯ គណនី Sorng Viseth បាននិយាយត្រង់ៗថា "He failed to crack down on the scam hubs at the beginning as it involves high

ranking people in his government!" សំណេរដើម - “គាត់បរាជ័យក្នុងការបង្ក្រាបបណ្តាញឆបោកតាំងពីដំបូង ព្រោះវាពាក់ព័ន្ធនឹងមនុស្សដែលមានឋានៈខ្ពស់ៗនៅក្នុងរដ្ឋាភិបាលរបស់គាត់!” សំណេរបកប្រែជាភាសាខ្មែរ។

- កិច្ចសហប្រតិបត្តិការក្នុងតំបន់៖ គណនី Phuong Vichea បានលើកឡើងពីករណីឆ្លងដែន ដោយកត់សម្គាល់ថា ប្រាក់នៃការឆបោកហូរកាត់ទីផ្សារមូលធនពណ៌ប្រផេះរបស់ប្រទេសថៃ។ គាត់សរសេរថា “Cambodia clean this scam out. Thailand has declared to be clean of scam but massive Scam money flow Thai Grey Capital and News about scam operations every week.” សំណេរដើម - “កម្ពុជាបានសម្អាតការឆបោកនេះ។ ប្រទេសថៃបានប្រកាសថាខ្លួនបានសម្អាតការឆបោក ប៉ុន្តែមានលំហូរប្រាក់យ៉ាងច្រើនពីការឆបោកពីទីផ្សារមូលធនពណ៌ប្រផេះរបស់ថៃ និងព័ត៌មានបានចុះផ្សាយអំពីប្រតិបត្តិការឆបោកជារៀងរាល់សប្តាហ៍។” សំណេរបកប្រែជាភាសាខ្មែរ។ មតិយោបល់នេះ បង្ហាញថាបញ្ហានេះមិនអាចដោះស្រាយបានដោយប្រទេសកម្ពុជាតែម្នាក់ឯងនោះទេ។

មតិយោបល់ចំនួនពីរផ្សេងទៀត ដែលមិនមានទំនោ។ គណនី Soury Mouy បានសរសេរថា "ខ្ញុំសូមអរគុណដែលនិយាយការពិត❤️" ការបង្ហាញការកោតសរសើរចំពោះបទសម្ភាសន៍របស់លោកនាយករដ្ឋមន្ត្រី។ ចំណែកឯ គណនី Sokry Moun បានសរសេរថា "សូមអោយមនុស្សលោកប្រកបរបរដោយសុចរិត🙏🙏🙏" ការអំពាវនាវខាងសីលធម៌សម្រាប់ការធ្វើការងារដោយស្មោះត្រង់។ គណនីទាំងពីរមិនបានស្នើដំណោះស្រាយគោលនយោបាយជាក់លាក់ណាមួយឡើយ។

> **ការសង្កេតទៅលើមតិយោបល់ដែលមិនមានទំនោ**
> ទោះបីជាមានមតិយោបល់មានត្រឹមតែ ៨ (០.៥៤%) ត្រូវបានចាត់ថ្នាក់ថាធម្មតា (មិនមានទំនោ) និងបានផ្តោតលើដំណោះស្រាយក៏ដោយ ក៏មតិយោបល់ទាំងនោះមានខ្លឹមសារបំផុតនៅក្នុងសំណុំទិន្នន័យរបស់មតិយោបល់ទាំងមូល។ សារមតិយោបល់ដែលបានគ្រប់ដណ្តប់ខ្លាំងក្នុង មតិយោបល់ទាំង ១៤៨៩ គឺនិយាយអំពីព្រំដែនកម្ពុជា-ថៃ ដែលមិនបានផ្តោតពីបៀបប្រយុទ្ធប្រឆាំងនឹងមជ្ឈមណ្ឌលឆបោកនោះទេ។ អ្នកសរសេរមតិយោបល់មិនមានទំនោគឺជាសំឡេងតែមួយគត់ដែលនិយាយដោយផ្ទាល់អំពីប្រធានបទនៃអត្ថបទផ្សព្វផ្សាយរបស់ AFP។

# ៤.សញ្ញានៃយុទ្ធនាការដែលមានការរៀបចំ

ផ្នែកនេះពន្យល់ពីមូលហេតុដែលសកម្មភាពនៃការផ្ទុសមតិយោបល់មើលទៅដូចមានការរៀបចំទុក និងមិនមែនពិតប្រាកដ។

## ៤.១ មតិយោបល់ចម្លង

មតិយោបល់មួយត្រូវបានចាត់ទុកថាជាមតិយោបល់ចម្លង គឺជាសំណោរទាំងស្រុងរបស់មតិយោបល់នោះ ដូចគ្នាបិះបិតនឹងមតិយោបល់ផ្សេងទៀត។ នៅក្នុងសំណុំទិន្នន័យនេះ ៧៩.៨% នៃមតិយោបល់គឺជាសារដែលត្រូវបានចម្លង។

មតិយោបល់ចម្លងទាំងនោះមិនមែនជារឿងចៃដន្យទេ។ វាត្រូវបានដកស្រង់ពីសំណុំទិន្នន័យសារចំនួន ១៦០ ដែលសារនីមួយៗត្រូវបានប្រើប្រាស់ដោយគណនីផ្សេងៗគ្នាជាច្រើន៖

| ចំនួននៃការចម្លង | សារ | ភាសា |
|---|---|---|
| ១៩ | កម្ពុជាគាំទ្រសន្តិភាព និងជ្រើសរើសច្បាប់អន្តរជាតិ ខណៈដែលថៃគិតតែអំណាច និងសង្គ្រាម បដិសេធច្បាប់អន្តរជាតិ។ | ខ្មែរ |
| ១៨ | កម្ពុជាបង្ហាញការស្មោះត្រង់ចំពោះសន្តិភាព និងជ្រើសរើសច្បាប់អន្តរជាតិ ក្នុងពេលដែលថៃបដិសេធច្បាប់អន្តរជាតិ និងធ្វើសង្គ្រាម។ | ខ្មែរ |
| ១៨ | កម្ពុជាគាំទ្រសន្តិភាព និងជ្រើសរើសច្បាប់អន្តរជាតិ តែថៃវិញជ្រើសរើសការប្រើកម្លាំង និងមិនគោរពច្បាប់អន្តរជាតិ។ | ខ្មែរ |
| ១៥ | "Thailand attacks it." | អង់គ្លេស |
| ១៤ | "Cambodia obeys law. Thailand breaks rules." | អង់គ្លេស |
| ១៤ | "Cambodia respects borders. Thailand crosses them." | អង់គ្លេស |
| ១៣ | "Thailand rejects peaceful solutions." | អង់គ្លេស |
| ១៣ | "Cambodia stands firm in law." | អង់គ្លេស |

សារទាំងនេះហាក់ដូចជាត្រូវបានសរសេរទុកមុន ហើយបានផ្តល់ឱ្យគណនីមួយចំនួនធំដើម្បីបង្ហោះ។ ការពិតដែលថាទាំងសារខ្លីៗ ("Thailand attacks it.") និងសារវែងៗដែលមានប្រយោគច្រើនត្រូវបានចែករំលែកដោយគ្មានការផ្លាស់ប្តូរណាមួយ ដែលបង្ហាញថា មតិយោបល់ត្រូវបានរៀបចំយ៉ាងប្រុងប្រយ័ត្ន។

### ៤.២ ការផ្ទុសយ៉ាងគំហុករយៈពេល ២ម៉ោង

តារាងពេលវេលាក្នុងផ្នែកទី ២ (និន្នាការមតិយោបល់តាមម៉ោង) បង្ហាញថា មតិយោបល់ដែលបានចម្លងស្ទើរតែទាំងអស់បានលេចឡើងក្នុងរយៈពេលត្រឹមតែពីរម៉ោងប៉ុណ្ណោះ។ ដូចការបង្ហាញជាក់ស្តែងខាងក្រោមនេះ៖

- មុនម៉ោង 21:00 UTC: ចំនួនសរុប ៤៩ មតិយោបល់ស្ទួន (៤.១% នៃមតិយោបល់ស្ទួនទាំងអស់)
- ម៉ោង 21:00–22:00 UTC: ចំនួនមតិយោបល់ស្ទួន ១១៣៩ (៩៥.៩% នៃមតិយោបល់ស្ទួនទាំងអស់)
- ក្រោយម៉ោង 23:00 UTC: សកម្មភាពបង្ហោះមតិយោបល់ធ្លាក់សឹងតែដល់សូន្យ

> **ហេតុអ្វីបានករណីនេះសំខាន់**
> នៅពេលដែលការបង្ហោះមួយទទួលបានមតិយោបល់ច្រើន ជាធម្មតាវាចូលមកយឺតៗក្នុងរយៈពេលជាច្រើនម៉ោង ដោយសារមនុស្សមកពីប្រទេស និងតំបន់ពេលវេលាផ្សេងៗគ្នាអានអត្ថបទ។ រលកនៃមតិយោបល់ដ៏ច្រើនសន្ធឹកសន្ធាប់ក្នុងរយៈពេលពីរម៉ោង បន្ទាប់មកឈប់ភ្លាមៗ មិនត្រូវគ្នានឹងឥរិយាបថធម្មតារបស់អ្នកអាននោះទេ។ វាស៊ីសង្វាក់គ្នា ជាមួយនឹងក្រុមគណនីដែលត្រូវបានគេបើកក្នុងពេលតែមួយ បង្ហោះសាររបស់ពួកគេ រួចហើយមកបិទវិញ។

## ៥. ការកំណត់បានការប្រើប្រាស់ Bot៖ ការវិភាគលើល្បឿននៃការវាយអត្ថបទ

សម្រាប់គណនីនីមួយៗដែលបានបង្ហោះច្រើនជាងមួយម្តង ការសិក្សានេះបានវាស់ស្ទង់ចំនួនវិនាទី នៃចន្លោះការផ្ទុសមតិយោបល់ និងចំនួនតួអក្សរដែលបង្ហោះនីមួយៗមាន។ នេះអនុញ្ញាតឱ្យមានការគណនាល្បឿនដែលពួកគេត្រូវការដើម្បីវាយអក្សរ។

> **ឯកសារយោង[1]៖ តើមនុស្សអាចវាយអក្សរបានលឿនប៉ុណ្ណា**
> មនុស្សធំជាមធ្យមវាយអក្សរប្រហែល ២០០ តួអក្សរ (Latin) ក្នុងមួយនាទី (ប្រហែល ៣ទៅ៤ តួអក្សរក្នុងមួយវិនាទី)។ អ្នកវាយអក្សរលឿនខ្លាំង (ការប្រកួតប្រជែង) អាចវាយបានប្រហែល ៦០០ តួអក្សរក្នុងមួយនាទី (ប្រហែល ១០ តួអក្សរក្នុងមួយវិនាទី)។ ល្បឿនដែលលើសពី ១៦ តួអក្សរក្នុងមួយវិនាទី (៩៥៥ cpm[2] - កំណត់ត្រាពិភពលោក) សម្រាប់អត្ថបទវែងមួយគឺមិនអាចទៅរួចទេសម្រាប់អ្នកវាយអក្សរធម្មតានោះ។

មានការបង្ហោះមតិយោបល់ចំនួនដប់មួយគូ ដែលគណនីដូចគ្នាបានបង្ហោះពីរដងក្នុងរយៈពេល ៦០ វិនាទី។ បង្ហាញក្នុងតារាងខាងក្រោម៖

---

[1] *Druide informatique inc. (2026).* Typing speed. *Typing Pal.* https://www.typingpal.com/en/documentation/school-edition/pedagogical-resources/typing-speed
[2] *Characters Per Minute (CPM): ចំនួនតួអក្សរក្នុងមួយនាទី*

| ឈ្មោះគណនី | ផូស | ចន្លោះវិនាទី | តួអក្សរផូសទី១ | តួអក្សរផូសទី២ | ចំនួនតួអក្សរក្នុង១វិនាទី | កម្រិតហានិភ័យ |
|---|---|---|---|---|---|---|
| **Jee Naa** | ២ | ៣ | ៦៣៧ | 637 | **៤២៤.៧** | **ខ្ពស់ខ្លាំង** |
| **Charntharn Lout** | ២ | ១៣ | ១៨៩១ | ១៨៧៩ | **២៩០.០** | **ខ្ពស់ខ្លាំង** |
| ปล่อยเปีย ปล่อยเปีย | ៤ | ៣៩ | ២២ | ២១៧៤ | **៥៦.៣** | **ខ្ពស់** |
| **Tanawat Pangpan** | ៤ | ៣៧ | ៧៧៩ | ៧៧៩ | **៤២.១** | **ខ្ពស់** |
| Swang Krajangta | ២ | ១៣ | ៧០ | ៥៧ | ៩.8 | មធ្យម |
| Keng Jing | ៣ | ៣៣ | ៩៦ | ៩៦ | ៥.៨ | មធ្យម |
| คน หลังฉาก | ៥ | ៤៩ | ២២០ | ១៦ | ៤.៨ | មធ្យម |
| Neang Run | ២ | ៣២ | ២១ | ៥០ | ២.២ | ទាប |
| مايا ساكورا الزهور العطرة | ៤ | ៥៥ | ៤៣ | ៣២ | ១.៤ | ទាប |
| Angkor Cambodia | ២ | ៣០ | ៨ | ២៨ | ១.២ | ទាប |

## ៥.១ សឹងតែច្បាស់ថា វាជាការផូសដោយប្រើប្រាស់កម្មវិធីស្វ័យប្រវត្តិ

### គណនី Jee Naa — ៤២៤.៧ តួអក្សរក្នុង១វិនាទី

គណនីនេះបានបង្ហោះសារដូចគ្នាចំនួន ៦៣៧ តួអក្សរពីរដង ដោយមានចន្លោះពេលត្រឹមតែ 3 វិនាទីប៉ុណ្ណោះ។ ដើម្បីផូសបានដោយការវាយអក្សរដោយដៃ តម្រូវឱ្យវាយអក្សរចំនួន ២៥៤៨ ពាក្យក្នុងមួយនាទី ដែលលឿនជាងអ្នកវាយអក្សរកំណត់ត្រាពិភពលោកជាង ៤០ ដង។ ការបង្ហោះទាំងពីរក៏ដូចគ្នាបេះបិទដែរ ដែលមានន័យថាអត្ថបទត្រូវបានចម្លង និងបិទភ្ជាប់ (copy និង past) មិនមែនវាយបញ្ចូលទេ។ គណនីនេះស្ទើរតែប្រាកដជាបានប្រើកម្មវិធីស្វ័យប្រវត្តិ។

### គណនី Charntharn Lout — ២៩០.០ តួអក្សរក្នុង១វិនាទី

គណនីនេះបានបង្ហោះសារពីរដែលស្រដៀងគ្នាខ្លាំង (ប្រហែល ១៨៨០ តួអក្សរក្នុងមួយសារ) ដែលមានចន្លោះពេលត្រឹមតែ ១៣ វិនាទីប៉ុណ្ណោះ។ សារទាំងនោះមានលេចចេញនូវកំហុសច្បាស់ផងដែរ៖ ពាក្យត្រូវបានបង្កើនទ្វេដងពេញមួយសារ ឧទាហរណ៍ “Thai Thai Army Army has has invaded invaded deeper deeper..."។ ទម្រង់នៃពាក្យស្ទួនៗ បែបនេះគឺជាសញ្ញាទូទៅនៃកំហុសក្នុងការបង្ហោះផ្អែកលើស្រ្គីប (script-based posting error) ពេលដែលអត្ថបទបានប្រើប្រាស់កម្មវិធីស្វ័យប្រវត្តិ (automation tool) ដំណើរការមិនបានត្រឹមត្រូវ។

### ៥.២ ទំនងជាប្រើប្រាស់កម្មវិធីស្វ័យប្រវត្តិ

គណនីពីរទៀតបង្ហាញពីល្បឿនដែលមិនទំនងជាការបង្ហោះដោយការវាយអក្សរដោយដៃធម្មតាទេ។ Tanawat Pangpan (42.1 តួអក្សរ/វិនាទី) បានបង្ហោះអត្ថបទ ៧៧៩ តួអក្សរដូចគ្នាពីរដងក្នុងរយៈពេល ៣៧ វិនាទី។ គណនី បល់ឯបើយ បានបង្ហោះសារ (៥៦.៣ តួអក្សរ/វិនាទី) ដែលមានចំនួន ២១៧៤ តួអក្សរ ត្រឹមតែ 39 វិនាទីបន្ទាប់ពីការបង្ហោះរយៈពេលខ្លីមួយ។ ជាសរុប គណនីទាំងពីរនេះ បានបង្ហោះសារជាច្រើនដង។

## ៦. គំរូឈ្មោះគណនី និងការវិភាគអត្តសញ្ញាណ

ផ្នែកនេះពិនិត្យមើល ថាតើអ្នកបង្ហោះមតិយោបល់សកម្មបំផុតជានរណា ឈ្មោះរបស់ពួកគេត្រូវបានសរសេរជាភាសាអ្វី និងថាតើឈ្មោះរបស់ពួកគេត្រូវគ្នានឹងភាសា និងខ្លឹមសារនៃមតិយោបល់របស់ពួកគេដែរឬទេ។ ឈ្មោះគណនីតែមួយមុខមិនអាចបញ្ជាក់ថាគណនីមួយក្លែងក្លាយបានទេ ប៉ុន្តែគំរូនៅក្នុងសំណុំទិន្នន័យបង្ហាញពីសញ្ញាមានសំខាន់ៗ ថាតើអ្នកណាដែលកំពុងនិយាយ និងថាតើគណនីណាមួយទំនងជាលាក់បាំងអត្តសញ្ញាណពិតរបស់ពួកគេ។

### ៦.១ ការបំបែកឈ្មោះគណនី

Account names across all 1,489 posts fall into four language groups: ឈ្មោះគណនីដែលបានបង្ហោះមតិយោបល់ទាំង ១៤៨៩ ត្រូវបានបែងចែកជាបួនក្រុមភាសា៖

| ឈ្មោះ ស្ក្រីប | ការបង្ហោះសរុប | ចំនួនគណនីជាក់លាក់ | ប្រភេទអត្ថបទដែលមានទំនោ |
|---|---|---|---|
| Latin / Romanised Khmer | ៩៦១ | ៩៣៨ | ចម្រុះ: ទំនោកម្ពុជា (២០៤) + ប្រឆាំង ហ៊ុន ម៉ាណែត (៦២) + ផ្សេងៗទៀត |
| Khmer script | ៤៨៨ | ៤៨៨ | ស្ទើតែទាំងអស់ មានទំនោមកកម្ពុជា តែនិយាយពីជម្លោះព្រំដែន |
| Thai script | ៣៦ | ២៦ | ១០០% អត្ថបទដែល ប្រឆាំងកម្ពុជា ឬប្រឆាំង ហ៊ុន ម៉ាណែត |
| Arabic script (mixed name) | ៤ | ២ | អត្ថបទសរសេរអង់គ្លេស ប្រឆាំង ហ៊ុន ម៉ាណែត |

### ៦.២ គណនីទាំង១០ ដែលមានសកម្មភាពផ្ទុសច្រើនជាងគេ

មានតែគណនីចំនួន ៣៦ ប៉ុណ្ណោះដែលត្រូវបានបង្ហោះច្រើនជាង១ម្តង។ តារាងខាងក្រោមបង្ហាញពីគណនីកំពូលៗទាំង ១០។ នេះជាចំណុចសំខាន់៖ អ្នកបង្ហោះដែលជាមនុស្សពិតទាំងអស់ ហាក់ឃើញថាជាអ្នករិះគន់រដ្ឋាភិបាល។ គណនីគាំទ្រកម្ពុជាតែមួយគត់ដែលបង្ហោះម្តងហើយម្តងទៀតគឺទំនងខ្លាំង ថាជាគណនី bot។

| ឈ្មោះគណនី | ការបង្ហោះ | Likes | ឈ្មោះស្គ្រីប | ភាសានៃមតិយោបល់ | ទំនោ |
|---|---|---|---|---|---|
| **คน หลังฉาก** | ៥ | ១៩ | Thai | English | ប្រឆាំងកម្ពុជា / រិះគន់ |
| **مايا ساكورا الزهور العطرة** | ៤ | ០ | Arabic | English | ប្រឆាំង ហ៊ុន ម៉ាណែត |
| **ปล่อยเปีย ปล่อยเปีย** | ៤ | ០ | Thai | Thai+English | ប្រឆាំងកម្ពុជា |
| **จิตรลดา อาจหาญ** | ៤ | ០ | Thai | English | ប្រឆាំងកម្ពុជា |
| **Tanawat Pangpan** | ៤ | ០ | Latin | Thai+English | ប្រឆាំងកម្ពុជា |
| **Keng Jing** | ៣ | ០ | Latin | English | ប្រឆាំង ហ៊ុន ម៉ាណែត |
| **Jee Naa** | ២ | ០ | Latin | English | ទំនោ កម្ពុជា (ការបង្ហោះប្រើប្រាស់ bot) |
| **Eno Enofive** | ២ | ១ | Latin | English | ប្រឆាំង ហ៊ុន ម៉ាណែត |
| **Sunrise Buser** | ២ | ០ | Latin | English | រិះគន់ / ចម្រុះ |
| **Chuti Mekanontchai** | ២ | ១៣ | Latin | Thai+English | ប្រឆាំង ហ៊ុន ម៉ាណែត |

> **Key Finding — The Only Repeat Pro-Cambodia Poster Is a Bot**
> ក្នុងចំណោមគណនីសកម្មទាំង ១០ មានគណនីចំនួន ៦ ក៏លេចឡើងក្នុងតារាងរកឃើញប្រើប្រាស់ bot (ផ្នែកទី ៥)។ ក្នុងចំណោមគណនីទាំងនេះ គណនី Jee Naa (ហានិភ័យខ្ពស់ណាស់ ៤២៤.៧ តួអក្សរ/វិនាទី) គឺជាអ្នកបង្ហោះសារគាំទ្រកម្ពុជាដដែលៗតែមួយគត់ ហើយ ស្ទើរតែប្រាកដច្បាស់ថា ប្រើប្រាស់ bot។ ទោះជាយ៉ាងណាក៏ដោយ គណនីប្រឆាំងកម្ពុជាពីរ — ปล่อยเปีย ปล่อยเปีย (ហានិភ័យខ្ពស់ ៥៦.៣ តួអក្សរ/វិនាទី) និង Tanawat Pangpan (ហានិភ័យខ្ពស់ ៤២.១ តួអក្សរ/វិនាទី) ក៏ត្រូវបានសម្គាល់ថាទំនងជាបង្ហោះដោយប្រើប្រាស់កម្មវិធីស្វ័យប្រវត្តិផងដែរ។ នេះបង្ហាញថាឥរិយាបថគួរឱ្យសង្ស័យនៃការប្រើប្រាស់ bot មិនមែនធ្វើតែចំពោះយុទ្ធនាការគាំទ្រកម្ពុជាទេ។ ភាគីទាំងសងខាងដែលបង្ហោះក្នុងផ្នែកមតិយោបល់នេះ មានគណនីដែលបង្ហាញសញ្ញានៃសកម្មភាពប្រើប្រាស់កម្មវិធីស្វ័យប្រវត្តិ។

## ៦.៣ ការវិភាគអត្តសញ្ញាណរវាងឈ្មោះ និងខ្លឹមសារ

នៅពេលដែលអក្សរនៃឈ្មោះគណនីមួយ មិនត្រូវគ្នាជាមួយភាសានៃការបញ្ចេញមតិ ឬខ្លឹមសាររបស់វាទេ វាកាន់តែបង្ហាញថាគណនីនោះកំពុងព្យាយាមបន្លំខ្លួនជាក្រុមផ្សេង។ លំនាំបែបដូចខាងក្រោមនេះត្រូវបានរកឃើញ៖

### គណនីដែលមានឈ្មោះថៃ - មិនសញ្ញានៃការលាក់បាំង

គណនីទាំង ២៦ ដែលមានឈ្មោះជាអក្សរថៃ បានបង្ហោះខ្លឹមសារប្រឆាំងនឹងប្រទេសកម្ពុជា ឬប្រឆាំងនឹងលោក ហ៊ុន ម៉ាណែត ហើយមិនមានការបង្ហោះខ្លឹមសារគាំទ្រកម្ពុជាឡើយ។ ពួកគេហាក់ដូចជាមិនបានលាក់បាំងអត្តសញ្ញាណរបស់ខ្លួននោះទេ។ ឈ្មោះជាភាសាថៃរបស់ពួកគេ គឺមានភាពស៊ីសង្វាក់គ្នាជាមួយនឹងជំហរប្រឆាំងនឹងកម្ពុជារបស់ពួកគេ។ ឧទាហរណ៍ដែលគួរឱ្យកត់សម្គាល់មានដូចជា៖

- **"คน หลังฉาก"** (មានន័យថា៖ "មនុស្សនៅពីក្រោយឆាក") — ជាគណនីទោលដែលសកម្មបំផុត (មានការបង្ហោះ ចំនួន៥ដង និងមានការ Like នៃការបង្ហោះ សរុបចំនួន ១៩)។ រាល់ការបង្ហោះទាំងអស់គឺធ្វើឡើងជាភាសាអង់គ្លេស មានខ្លឹមសារច្បាស់លាស់ និងផ្តោតលើការចោទប្រកាន់អំពីទំនាក់ទំនងរវាងគ្រួសារលោក ហ៊ុន សែន និងប្រតិបត្តិការឆបោក។
- **"เขมร ต่ำ"** ឈ្មោះជាអក្សរថៃដែលមានន័យថា "ខ្មែរជាន់ទាប" — ជាពាក្យប្រមាថ និងបង្ខូចកេរ្តិ៍ឈ្មោះយ៉ាងធ្ងន់ធ្ងរចំពោះជនជាតិខ្មែរ ដែលបានប្រើប្រាស់ធ្វើជាឈ្មោះគណនី។ ការប្រើប្រាស់ ខ្លឹមសារនៃការរិះគន់ប្រឆាំងនឹងកម្ពុជាជាភាសាអង់គ្លេស។
- **"ฮุนเซนเตอร์"** ("Hun Sen Centre") — ជាឈ្មោះបែបចំអក។ មតិយោបល់ត្រូវបានសរសេរជាភាសាវៀតណាម មិនមែនភាសាខ្មែរ និងមិនមែនភាសាអង់គ្លេស ដូច្នេះ មតិយោបល់នេះមិនស្ថិតក្នុងការវិភាគ (ត្រូវបានចាត់ជាប្រភេទមតិយោបល់ “មិនអាចចាត់ថ្នាក់បាន”)។
- **"ขุน ห้วยแม่ต้า"** — បានបង្ហោះការបញ្ចេញមតិជាភាសាថៃមួយដែលមានការចូលចិត្តចំនួន ១៣៖ **"นักแสดงรางวัลตุ๊กตาทอง"** ដែលមានន័យថា "តារាសម្តែងដែលឈ្នះពានរង្វាន់តុក្កតាមាស" — ជាការចំអកឱ្យលោក ហ៊ុន ម៉ាណែត ថាជាអ្នកសម្តែងជាជាងជាអ្នកដឹកនាំ។

## ឈ្មោះកាត់បូកបញ្ចូលគ្នាអារ៉ាប់+ជប៉ុន — លទ្ធភាពនៃការបិទបាំងអត្តសញ្ញាណ

"مايا ساكورا الزهور العطرة" — ឈ្មោះនេះរួមបញ្ចូលភាសាអារ៉ាប់ ("ម៉ាយ៉ានៃផ្កាដែលមានក្លិនក្រអូប") ជាមួយនឹងពាក្យជប៉ុន "sakura" (ផ្កាសាគូរ៉ា)។ គណនីនេះបានបង្ហោះមតិប្រឆាំងនឹងលោក ហ៊ុន ម៉ាណែត ចំនួន ៤ដង ដែលផ្សេងៗពីគ្នាជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ ឈ្មោះដែលមានបង្កក់ភាសាគ្នានេះ មិនត្រូវគ្នានឹងអត្តសញ្ញាណជាក់លាក់ណាមួយឡើយ ហើយអាចជាការព្យាយាមជៀសវាងការផ្សារភ្ជាប់ទៅនឹងប្រទេសជាក់លាក់ណាមួយ។

## Natthakit Pa — ការកំណត់គោលដៅអ្នកស្តាប់ ឬ ការបន្លំអត្តសញ្ញាណ?

ឈ្មោះ "Natthakit" គឺជាឈ្មោះថៃ។ គណនីនេះបានបង្ហោះមតិប្រឆាំងនឹងកម្ពុជាជាភាសាអង់គ្លេស។ បន្ទាប់មកបកប្រែខ្លឹមសារដដែលនោះទៅភាសាខ្មែរ។ នេះបង្ហាញពីលំនាំច្បាស់ថា គណនីនេះចង់ឱ្យទាំងអ្នកអានដែលនិយាយភាសាអង់គ្លេស និងអ្នកអានដែលនិយាយភាសាខ្មែរបានឃើញសាររបស់ខ្លួន។ ការសរសេរជាភាសាខ្មែរធ្វើឱ្យខ្លឹមសារនោះកាន់តែងាយស្រួលសម្រាប់ជនជាតិខ្មែរក្នុងការអាន និងជឿជាក់។ នេះត្រូវបានគេហៅថាជាការកំណត់គោលដៅអ្នកស្តាប់ (audience targeting)។ គណនីនេះមិនបានព្យាយាមលាក់បាំងថាខ្លួនជាជនជាតិថៃនោះទេ។ វាគ្រាន់តែធ្វើឱ្យសាររបស់ខ្លួនមានជាភាសាកម្ពុជា ដើម្បីអាចទៅដល់អ្នកអានបានកាន់តែច្រើន។

## គណនីដែលមានឈ្មោះជាអក្សរឡាតាំង បង្ហោះជាភាសាខ្មែរ (១៨៤ ការបង្ហោះ)

ការបង្ហោះចំនួន ១៨៤ មកពីគណនីដែលមានឈ្មោះជាអក្សរឡាតាំង ដែលបានបង្ហោះមតិយោបល់យុទ្ធនាការគាំទ្រកម្ពុជាជាភាសាខ្មែរ។ ឈ្មោះទាំងនោះមានដូចជា "Chiva Rina", "Doeun Chenda", "Sien Sobat", "Sreypov Ly" គឺជាការសរសេរតាមសូរសព្ទអក្សរឡាតាំងនៃឈ្មោះខ្មែរ។ មិនមានភស្តុតាងនៃការលាក់បាំងអត្តសញ្ញាណនោះទេ។ ឈ្មោះទាំងនេះដូចជាគណនីរបស់ជនជាតិខ្មែរដែលប្រើប្រាស់ឈ្មោះរបស់ពួកគេជាទម្រង់អក្សរឡាតាំង។

"AnonymousTH" (user ID: 61560383947074) ប្រើប្រាស់ពាក្យ "Anonymous" នៅក្នុងឈ្មោះរបស់ខ្លួន។ នេះគឺជាជម្រើសដោយចេតនាក្នុងការលាក់បាំងអត្តសញ្ញាណពិតប្រាកដរបស់គណនី។ អក្សរ "TH" អាចបង្ហាញពីការផ្សារភ្ជាប់ទៅនឹងប្រទេសថៃ ប៉ុន្តែចំណុចនេះមិនអាចបញ្ជាក់ច្បាស់នោះទេ។ គណនីនេះបានបង្ហោះសារថា "He's a PM. or an actor?" ដែលជាមតិយោបល់ទទួលបានការចូលចិត្តច្រើនជាងគេបំផុតនៅក្នុងសំណុំទិន្នន័យ (១២ likes)។ ខុសប្លែកពីមតិយោបល់គាំទ្រកម្ពុជាដែលត្រូវជាសារចម្លងបន្តគ្នា នេះហាក់ដូចជារិះគន់ពិតរបស់បុគ្គលម្នាក់។ ទោះជាយ៉ាងណាក៏ដោយ គណនីនេះបានជ្រើសរើសដោយចេតនាមិនបង្ហាញថាខ្លួនជានរណាឡើយ។

## ៧. លទ្ធផល នៃការស្រាវជ្រាវ

### ការរកឃើញទី១៖ មតិយោបល់ (Comment) ត្រូវបានប្រើប្រាស់ដើម្បីបង្វែរពីប្រធានបទដើម

> ប្រធានបទចម្បងនៃអត្ថបទរបស់ទីភ្នាក់ងារសារព័ត៌មាន AFP គឺអំពីមជ្ឈមណ្ឌលឆបោកនៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ មតិយោបល់ដែលបានបង្ហោះញឹកញាប់បំផុត គឺនិយាយអំពីប្រធានបទផ្សេងទៅវិញ៖ នោះគឺវិវាទព្រំដែនរវាងកម្ពុជា និងថៃ។ នេះគឺជាបច្ចេកទេសមួយដែលគេហៅថា "ការបង្ហោះពន្លិចប្រធានបទ" (topic flooding) គឺជាការបំពេញការបង្ហោះ ជាមួយនឹងប្រធានបទ ដែលមិនទាក់ទងនឹងប្រធានបទរបស់អត្ថបទដើម ដើម្បីរុញការបញ្ចេញមតិពិតប្រាកដចេញ។ ផ្នែកបញ្ចេញមតិ (comment) នេះ មិនគួរត្រូវបានចាត់ទុកថាជាការឆ្លុះបញ្ចាំងពីមតិសាធារណៈលើបញ្ហាមជ្ឈមណ្ឌលឆបោកនោះឡើយ។

### ការរកឃើញទី២៖ ជិត ៨០% នៃមតិយោបល់ (Comments) ត្រូវបានចម្លងបន្តគ្នា

> នៅក្នុងការពិភាក្សាលើប្រព័ន្ធអ៊ីនធឺណិតធម្មតា មតិយោបល់ដែលមានលក្ខណៈចម្លងគ្នាដូចបេះបិទ គឺមានចំនួនតិចជាង ៥% ប៉ុណ្ណោះ។ ប៉ុន្តែនៅក្នុងទិន្នន័យនេះ មតិយោបល់ចំនួន ៧៩.៨% គឺជាការចម្លងគ្នាដូចបេះបិទ។ នេះគឺជាភស្តុតាងដ៏រឹងមាំដែលបង្ហាញថា មតិយោបល់ទាំងនេះត្រូវបានបង្កើតឡើងដោយក្រុមដែលមានការចាត់តាំង ដោយប្រើប្រាស់នូវសារដែលបានសរសេរទុកជាមុន ហើយវាមិនមែនជាការបញ្ចេញមតិផ្ទាល់ខ្លួនរបស់សាធារណជនទូទៅនោះទេ។

### ការរកឃើញទី៣៖ រាល់ការចម្លង (comment) បន្តគ្នាទាំងអស់បានលេចឡើងក្នុងរយៈពេល ២ ម៉ោង

> ការបញ្ចេញមតិបានចាប់ផ្តើមយឺតៗនៅពេលដែលអត្ថបទរបស់ AFP ត្រូវបានចុះផ្សាយ បន្ទាប់មកមានរលកនៃការបញ្ចេញមតិយ៉ាងគំហុកបានមកដល់នៅចន្លោះម៉ោង ២១:០០ និង ២២:០០ UTC ដែលមានមតិយោបល់រហូតដល់ ៨១៤ ក្នុងរយៈពេលតែមួយម៉ោងប៉ុណ្ណោះ។ បន្ទាប់ពីម៉ោង ២៣:០០ UTC ចំនួននេះបានធ្លាក់ចុះមកជិតដល់សូន្យវិញ។ លំនាំនេះគឺស្របគ្នាទៅនឹងការបង្ហោះសារជាទ្រង់ទ្រាយធំដែលមានការចាត់តាំងជាក្រុម ហើយវាមិនមែនជាការចូលរួមបញ្ចេញមតិដោយពិតប្រាកដរបស់សាធារណជននោះទេ។

### ការរកឃើញទី៤៖ កម្មវិធីកុំព្យូទ័រត្រូវបានប្រើប្រាស់ដើម្បីបង្ហោះសារ

> មានគណនីយ៉ាងហោចណាស់ពីរ បានបង្ហោះសារយ៉ាងវែងក្នុងល្បឿនមួយដែលមនុស្សមិនអាចវាយអត្ថបទបានទាន់។ គណនីមួយ (ឈ្មោះ Jee Naa) បានបង្ហោះមតិយោបល់ដែលមានចំនួន ៦៣៧ តួអក្សរ ចំនួនពីរដងក្នុងរយៈពេលត្រឹមតែ ៣ វិនាទីប៉ុណ្ណោះ។ ចំណែកគណនីមួយទៀត (ឈ្មោះ Charntharn Lout) បានបង្ហោះសារដែលបង្ហាញឱ្យឃើញពីកំហុសបច្ចេកទេស (script error) ដែលក្នុងនោះពាក្យពេចន៍ត្រូវបានសរសេរស្ទួនដោយអចេតនា។ ទាំងនេះគឺជាសញ្ញានៃការប្រើប្រាស់ឧបករណ៍កម្មវិធីស្វ័យប្រវត្តិ (automated software tools)។

### ការរកឃើញទី៥៖ សំឡេងរិះគន់ត្រូវបានបំបិទដោយការបង្ហោះពន្លិច

> មានមតិយោបល់ត្រឹមតែ ៧១ ប៉ុណ្ណោះ (៤.៨%) ដែលបានរិះគន់លោក ហ៊ុន ម៉ាណែត ឬបង្ហាញការសង្ស័យលើជំហររបស់រដ្ឋាភិបាល។ មតិយោបល់ទាំងនេះហាក់ដូចជាចេញពីឆន្ទៈពិតប្រាកដ និងត្រូវបានសរសេរដោយបុគ្គលម្នាក់ៗ។ ចំនួននេះគឺតិចតួចខ្លាំងណាស់ បើធៀបនឹងសារគាំទ្រកម្ពុជាដែលត្រូវបានចម្លងបន្តគ្នា។ អ្នកអានដែលមើលទៅលើផ្នែកបញ្ចេញមតិ (comment) នឹងទទួលបានរូបភាពមិនពិតអំពីមតិសាធារណៈ។

# ៨ ការផ្តល់អនុសាសន៍

## ៨.១ សម្រាប់អង្គការសង្គមស៊ីវិល (CSOs)

- រក្សាទុកច្បាប់ចម្លងនៃផ្នែកបញ្ចេញមតិ (comment) ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ Facebook អាចនឹងលុប ឬលាក់មតិយោបល់ទាំងនោះនៅពេលក្រោយ។ ការថតរូបភាពអេក្រង់ (Screenshots) និងការទាញយកទិន្នន័យចេញ (data exports) សម្រាប់ជាភស្តុតាងដែលមានប្រយោជន៍នៅពេលក្រោយ។
- រាប់ចំនួនមតិយោបល់ដែលជាការចម្លងគ្នាដូចបេះបិទ។ ប្រសិនបើលើសពី ៥០% នៃមតិយោបល់គឺជាអត្ថបទដូចគ្នា នេះគឺជាសញ្ញាព្រមាននៃយុទ្ធនាការដែលមានការចាត់តាំងជាក្រុម។
- ពិនិត្យមើលលំនាំពេលវេលា។ ប្រសិនបើមតិយោបល់ភាគច្រើនមកដល់ក្នុងរយៈពេលខ្លី និងគំហុក ឧទាហរណ៍រាប់រយមតិយោបល់ក្នុងរយៈពេលតែមួយម៉ោង។ នេះមិនមែនជាឥរិយាបថតាមធម្មតានោះទេ។
- កុំប្រើប្រាស់ចំនួនមតិយោបល់ ដើម្បីវាស់ស្ទង់មតិសាធារណៈ។ ចំនួនមតិយោបល់ដ៏ច្រើន មិនមែនមានន័យថាមានការគាំទ្រពីសាធារណជនច្រើននោះទេ។ ចំនួនដ៏ច្រើននេះអាចត្រូវបានបង្កើតឡើងដោយការក្លែងបន្លំ។
- រាយការណ៍អំពីយុទ្ធនាការដែលមានការចាត់តាំងទ្រង់ទ្រាយធំទៅកាន់ក្រុមហ៊ុន Meta ដោយប្រើប្រាស់ឧបករណ៍រាយការណ៍របស់វេទិកានេះ។ រក្សាទុកឯកសារយោងនៃការរាយការណ៍របស់អ្នកសម្រាប់ជាភស្តុតាង។
- ចែករំលែកការរកឃើញរបស់អ្នកជាសាធារណៈ នៅពេលដែលមានសុវត្ថិភាពក្នុងការធ្វើបែបនេះ។ ការបង្ហាញតម្លាភាព ជួយឱ្យសាធារណជនយល់ដឹងអំពីអ្វីដែលកំពុងកើតឡើងនៅលើប្រព័ន្ធអ៊ីនធឺណិត។

### ៨.២ សម្រាប់អ្នកនយោបាយ និងបុគ្គលសាធារណៈ

- កុំបណ្តោយឱ្យរលកនៃមតិយោបល់ដែលត្រូវបានចម្លងបន្តគ្នា ធ្វើឱ្យអ្នកផ្លាស់ប្តូរជំហរសាធារណៈរបស់ខ្លួន។ មតិយោបល់ទាំងនេះ ប្រហែលជាមិនមែនជាការឆ្លុះបញ្ចាំងពីមតិសាធារណៈពិតប្រាកដនោះទេ។
- មុននឹងឆ្លើយតបទៅនឹងសម្ពាធនៅលើប្រព័ន្ធអ៊ីនធឺណិត សុំឱ្យក្រុមការងាររបស់អ្នកពិនិត្យមើលថាតើផ្នែកបញ្ចេញមតិ (comment) បង្ហាញពីសញ្ញានៃយុទ្ធការដែលមានការរៀបចំទុកដែរឬទេ។
- ប្រសិនបើទំព័រ (page) របស់អ្នកត្រូវបានកំណត់គោលដៅដោយយុទ្ធនាការដែលមានការរៀបចំទុក សូមពិចារណាធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ។ ពន្យល់ពីអ្វីដែលអ្នកបានរកឃើញ។ នេះនឹងជួយកាត់បន្ថយឥទ្ធិពលនៃយុទ្ធនាការនោះ។
- រក្សាទុកនូវរាល់មតិយោបល់ដែលមានសកម្មភាពគួរឱ្យសង្ស័យ។ ករណីដែលយើងបានចងក្រងជាឯកសារទុក អាចប្រើប្រាស់ជាភស្តុតាងឲ្យការទទួលខុសត្រូវនាពេលក្រោយ។
- ទាក់ទងទៅតាមបណ្តាញផ្តល់ជំនួយរបស់ក្រុមហ៊ុន Meta ប្រសិនបើអ្នកជឿថាទំព័ររបស់អ្នកកំពុងត្រូវបានកំណត់គោលដៅដោយសកម្មភាពមិនប្រក្រតី (inauthentic activity)។

## ៩. វិធីសាស្ត្រសិក្សា

- **ទិន្នន័យ៖** មតិយោបល់ (comments) ចំនួន ១,៤៨៩ ត្រូវបានប្រមូលពីការបង្ហោះលើ Facebook របស់ AFP ដែលមានលេខសម្គាល់ (ID) 1343523617820612។ រាល់កំណត់ត្រានីមួយៗ រួមមានអត្ថបទមតិយោបល់, លេខសម្គាល់អ្នកប្រើប្រាស់ (user ID), ឈ្មោះអ្នកប្រើប្រាស់, ចំនួន like, និងពេលវេលានៃការបង្ហោះ (comment post time stamp)។
- **ការរកឃើញខ្លឹមសារស្ទួន៖** ប្រើប្រាស់វិធីសាស្ត្រនៃការផ្ទៀងផ្ទាត់ពាក្យក្នុងអត្ថបទថាដូចគ្នាទាំងស្រុង។ អត្ថបទណាដែលមានក្នុងជួរដេក (row) ចាប់ពីពីរ ឬច្រើនឡើងទៅ ត្រូវបានរាប់ថាជាខ្លឹមសារស្ទួន។ រាល់អត្ថបទដែលស្រដៀងគ្នាខ្លាំង ឬការប្តូរឃ្លាខ្លះៗមិនត្រូវបានរាប់បញ្ចូលនោះទេ ដូច្នេះចំនួន ៧៩.៨% គឺជាការប៉ាន់ស្មានកម្រិតទាបបំផុត។ ចំនួនពិតប្រាកដនៃខ្លឹមសារដែលមិនមែនជាសំណេរផ្ទាល់ខ្លួនអាចមានកម្រិតខ្ពស់ជាងនេះ។
- **និន្នាការតាមម៉ោង៖** ជួរឈរ (column) "ពេលវេលាដែលបានបង្កើត" (created_time) ត្រូវបានបម្លែងទៅជាទម្រង់កាលបរិច្ឆេទ និងពេលវេលា ហើយត្រូវបានចងក្រងជាក្រុមតាមម៉ោង ដើម្បីបង្កើតជាគំនូសតាង "មតិយោបល់ក្នុងមួយម៉ោង" នៅក្នុងផ្នែកទី ២។
- **ការរកឃើញគណនីស្វ័យប្រវត្តិ (Bot):** សម្រាប់គណនីដែលមានការបង្ហោះចាប់ពីពីរដងឡើងទៅ ចន្លោះពេលរវាងការបង្ហោះបន្តបន្ទាប់គ្នាត្រូវបានវាស់វែង។ ចំនួនតួអក្សរសរុបនៃការបង្ហោះទាំងពីរ ត្រូវបានចែកនឹងចំនួនវិនាទី ដើម្បីរកមើលអត្រា "ចំនួនតួអក្សរក្នុងមួយវិនាទី"។
- **កម្រិតកំណត់នៃការសិក្សា៖** ការសិក្សានេះផ្អែកលើតែទិន្នន័យមតិយោបល់ជាសាធារណៈប៉ុណ្ណោះ។ ដើម្បីបញ្ជាក់ថាគណនីជាក់លាក់ណាមួយគឺជាគណនីក្លែងក្លាយ ចាំបាច់ត្រូវមានលទ្ធភាពចូលទៅកាន់ទិន្នន័យកម្រិតប្រព័ន្ធ (អាសយដ្ឋាន IP, ព័ត៌មានឧបករណ៍, កាលបរិច្ឆេទបង្កើតគណនី)។ ការរកឃើញនៅទីនេះគឺជាសូចនាករដ៏រឹងមាំ ប៉ុន្តែគួរត្រូវបានចាត់ទុកថាជាមូលដ្ឋានសម្រាប់ការស៊ើបអង្កេតបន្ថែម មិនមែនជាសេចក្តីសន្និដ្ឋានដាច់ខាតនោះទេ។
- **សម្គាល់លើភាសា៖** មតិយោបល់ជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស និងខ្មែរ មិនត្រូវបានវិភាគរកប្រភេទមតិនោះទេ ហើយត្រូវបានដាក់ចូលក្នុងប្រភេទ "មិនអាចចាត់ថ្នាក់បាន" (Unclassifiable)។ នេះមានន័យថា ទ

ស្បូនះមួយចំនួនដែលបញ្ចេញជាភាសាថៃ អារ៉ាប់ ឬភាសាផ្សេងទៀត មិនត្រូវបានបញ្ចូលក្នុងតារាងបែងចែកប្រភេទមតិយោបល់នោះទេ។

*បញ្ចប់របាយការណ៍ | ២ មីនា ២០២៦ | សម្រាប់សាធារណៈជនប្រើប្រាស់*